# អំពីពាក្យ «គង្ហីង»

យើងប្រទះឃើញវត្តមាន នាងគង្ហីងព្រះធរណី នៅក្នុងសង្គមខ្មែរច្រើនកន្លែងដូចជាគំនូរឈុតព្រះពុទ្ធផ្ចាញ់មារ កិច្ចប្រុងពលី[១] សន្ទឹកពពិល និងជាចម្លាក់ទោលដូចនៅរង្វង់មូលនាងគង្ហីងជាដើម។ ត្រង់ឈុតផ្ចាញ់មារ ឬ មារវិជ័យ យើងសង្កេតឃើញមាននៅប្រទេសកម្ពុជា ថៃ ឡាវ និងភូមា ដែលនិយមគូរឬឆ្លាក់រូបនាងគង្ហីងព្រះធរណីផុសក្រោមបល្ល័ង្កវ័ត្នច្បូតសក់បញ្ចេញទឹក។ តាមចំណេះដឹងពុទ្ធប្រវត្តិបែបអ្នកស្រុកអាស៊ីអាគ្នេយ៍ នៅមុនពេលដែលព្រះអង្គត្រាស់ដឹង ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្ស លើស្បូវភ្លាំងដែលសោត្ថិយព្រាហ្មណ៍ថ្វាយ ក្លាយជាបល្ល័ង្កវ័ត្នផុសទ្រព្រះអង្គ។ មារនិងសេនាវេហ៍ពលទាំងឡាយក៏មកផ្ចាញ់ផ្ចាលព្រះអង្គ ថាបល្ល័ង្កវ័ត្នទ្រង់កំពុងគង់លើនោះជារបស់មារាធិរាជ គឺមានវេហ៍ពលមារទាំងឡាយជាសាក្សី។ ព្រះពុទ្ធត្រាស់ថា បល្ល័ង្កវ័ត្ននេះកើតឡើងពីការសន្សំបារមីរបស់ព្រះអង្គអនេកជាតិ។ មារបន្តផ្ចាញ់ផ្ចាលរកអ្នកជាសាក្សី ទើបនាងគង្ហីងព្រះធរណីផុសមក ច្បូតសក់ជាទឹកលិចលង់ពួកមារនោះទៅ។ នាងគង្ហីងព្រះធរណី ជាតំណាងឱ្យព្រះធរណីជាសាក្សី ចំណែកឯទឹកដែលនាងច្បូតចេញពីសក់ តំណាងឱ្យទឹកដែលព្រះពុទ្ធអង្គតែងតែប្រួចលើព្រះធរណីក្នុងការសន្សំបារមីជាអនេកជាតិ គឺថាសូម្បីទឹកដែលព្រះអង្គប្រួចកន្លងមកនោះ ក៏អាចពន្លិចពួកមារឱ្យអន្តរធានបានដែរ[២]។ តាមពុទ្ធប្រវត្តិក្នុងគម្ពីរព្រះត្រៃបិដក ពុំមាននាងគង្ហីងព្រះធរណីនោះទេ គឺព្រះពុទ្ធអង្គចង្អុលផែនដីជាសាក្សី(ភូមិស្បស់) ផែនដីក៏កក្រើករញ្ជួយ ឯពួកមារក៏រលាយបាត់អស់ទៅ។ នាងគង្ហីងនេះ ទំនងជាការបន្ថែមបែបអ្នកស្រុកនៅអាស៊ីអាគ្នេយ៍ប៉ុណ្ណោះ។

នៅក្នុងសិលាចារឹកខ្មែរជាច្រើននៅប្រាសាទបាយ័ន មានសិលាចារឹកមួយផ្ទាំងចុះលេខ K.293-40 ចារឹកថា «វ្រះភគវតិធរណិ» សម្រួលមកថា ព្រះភគវតីធរណី ឬ ព្រះនាងធរណី ឬមានឈ្មោះផ្សេងទៀតជា ភូមិទេវី ឬ ភូមី ជាដើម ដែលគេស្គាល់ថាជាទេពរក្សាដីក្នុងសាសនាព្រាហ្មណ៍។ ចំណែកឯនៅក្នុងពុទ្ធសាសនា ពុំមានទេពរក្សាដីទេ។ ហេតុនេះ

---

[១] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/574

[២] សូមអានបន្ថែម៖ http://www.yosothor.org/publications/khmer-renaissance/chapter-two/pchanh-mea.html

អត្ថបទដោយ៖ លោក ហ៊ិន ឈុនតេង

ហើយ ទើបខ្មែរបង្កើតជារូបរាងឡើងជាតំណាង ដែលហៅថា «នាងគង្ហីង»។ នាងគង្ហីង គឺជាដី មិនមែនជាទេពរក្សាដីនោះទេ គ្រាន់តែគេធ្វើឡើងជារូបតំណាងឱ្យមានលក្ខណៈដូចមនុស្ស[៣] ដូចយើងឃើញតាមរូបគំនូរ ចម្លាក់ រូបសូនជាដើម។

បើយើងពិនិត្យលើពាក្យសព្ទវិញ ពាក្យ «គង្ហីង» ពុំមានកត់ត្រាជាមេពាក្យនៅក្នុងវចនានុក្រមខ្មែរឡើយ គឺមានតែក្នុងសេចក្ដីពន្យល់ពាក្យ «ធរណី» ប៉ុណ្ណោះ[៤] ទោះបីជាអ្នកស្រុកជាទូទៅស្គាល់ពាក្យនេះក្ដី។ ខ្មែរយើងរមែងហៅថា «នាងគង្ហីងព្រះធរណី» ហៅខ្លីថា «នាងគង្ហីង» ឬក៏ «នាងហ៊ីងព្រះធរណី» ហៅខ្លីថា «នាងហ៊ីង»។ តើពាក្យនេះវិវត្តមកពីពាក្យអ្វី? មានដើមកំណើតមកពីណា?

តាមរយៈការសិក្សាសិលាចារឹកភាសាខ្មែរបុរាណ យើងដឹងថាពាក្យ «គង្ហីង» វិវត្តចេញមកពីពាក្យបុរាណសម័យមុនអង្គរថា «កន្ហេង៑» ឬ «កញ្ហេង៑» ដែលមកដល់សម័យអង្គរ ពាក្យនេះវិវត្តមកជា «កន្ហ្យង៑» ឬ «កន្ហ្យាង៑»។ ពាក្យទាំងនេះបង្កើតចេញមកពីពាក្យឫស «ហេង៑» «ហ្យង៑» «ហ្យាង៑» ដែលមានន័យថាខ្លាំង ពូកែ ខ្ពង់ខ្ពស់ ច្រើនប្រើជាឋានន្តរនាមរបស់នារី ឬក្សត្រី នៃវណ្ណៈអភិជនឬរាជវង្សានុវង្ស។ លោក ម៉ៃឃើល វីឃើរី និងលោក ហ្វីលីព ជេន្នើរ យល់ថាពាក្យនេះមានទំនាក់ទំនងជាមួយពាក្យជ្វាបុរាណថា «ហ្យង៑» (hyaṅ) និងពាក្យចាម្ប «យង៑» (yaṅ) «យាង៑» (yāṅ) ជាពាក្យសម្គាល់អ្វីដែលពិសិដ្ឋត្រូវនឹងពាក្យខ្មែរទំនើបថា «ព្រះ»[៥]។ យ៉ាងនេះក្ដីយើងក៏អាចមើលឃើញថាពាក្យ «កន្ហេង៑» នេះ ក៏អាចមានពាក្យឫស «ខេង៑» មានន័យថាខែង ខែងរែង ផងដែរ។

ពាក្យ «កន្ហេង៑» ឬ «កញ្ហេង៑» នៅសម័យមុនអង្គរ ជាឋានន្តរនាមសម្រាប់សម្គាល់ស្ត្រីក្នុងវណ្ណៈអភិជន មានដូចជាក្សត្រីឬព្រះអង្គម្ចាស់ក្សត្រីជាដើម[៦]។ ពាក្យនេះក៏មានប្រើជាសមាសនាមសម្រាប់ឋានន្តរនាមផង ដូចក្នុងសិលាចារឹកក្រាំងព្រះពុទ្ធ K.1413 មាន

[៣] ញ៉ឹម សុជាវិទ្ធ ២០២០, https://ams.com.kh/khmercivilization/detail/574។

[៤] ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧, ធរណី (ធរៈនី) ន. ( សំ. បា. ) ផែនដី។ *រកស៊ីកកាយធរណី, ព្រះធរណី។ នាងធរណី គឺនាងគង្ហីងព្រះធរណី។*

[៥] Michael Vickery 1998 & Philip Jenner 2009: 9។

[៦] ឡុង សៀម ១៩៩៧: ៥១។

ឋានន្តរនាម «កញ្ញហេងអញ្ញ» ដែលជាស្ត្រីវណ្ណៈអភិជន ជាអ្នកទំនុកបម្រុងពិធីបូជានៅប្រាសាទ[៧]។ លុះមកដល់សម័យអង្គរ ពាក្យនេះប្រើជាពាក្យសមាសក្នុងឋានន្តរនាម «កន្សៀងកំម្រតេងអញ» មានន័យថា «ព្រះអង្គម្ចាស់ក្សត្រី»។ យើងសូមលើកជាឧទាហរណ៍ខ្លះៗចេញពីសិលាចារឹកខ្មែរបុរាណដូចក្នុងសិលាចារឹកនៅខេត្តផ្សារដែក K.9 មានចារឹកឃ្លាថា «ស្រេអំនោយកញ្ចេងវ្រះអញលាងគុសអាយតវ្រះកម្រតាងអញគ្រិកដាររវិវេគួរ...» (K.9:9-10) ដែលអាចសម្រួលថា «ស្រែជាអំណោយរបស់កញ្ចេងព្រះអញលាងគុសថ្វាយចំពោះព្រះគម្តែងអញស្រីកដាររវិវេស្វរ»។ សិលាចារឹកវត្តព្រះឥន្ទកោសិយ K.263 ចារឹកថា «ខ្ញុំជំនូនិកនិហ្សងកម្រតេងអញឥន្ទ្រលក្ស្មី» (K.263D:39) ដែលអាចសម្រួលបានថា «ខ្ញុំ(បម្រើជា)ជំនូនរបស់កន្ទេងគម្តែងអញឥន្ទ្រលក្ស្មី»។ ជាសរុបមក យើងឃើញថាពាក្យនេះ ប្រើសម្រាប់តែមនុស្សស្រីតែប៉ុណ្ណោះ កាលពីសម័យបុរាណ។

ពាក្យ «កន្ទេង» ឬ «កន្សៀង» នេះបានវិវត្តជាពាក្យ «គង្ហីង» និង «កំហែង» ក្នុងភាសាខ្មែរទំនើប។ នឹងយល់ពីការវិវត្តនោះ ត្រូវចាប់អារម្មណ៍ថា «ៀ» ពីសម័យបុរាណសម្រាប់ការកត់ត្រាពាក្យខ្មែរ មានបម្រែបម្រួលច្រើន គឺអាចទៅជាស្រៈ «េ» ផង ស្រៈ «ៀ»ផង និងស្រៈ «ី» ផង ។ល។ ដូចជាសំណេរពាក្យ «វ្រៀង» ពីបុរាណ ក្លាយមកជាពាក្យទំនើបថា «ព្រីង»។ នាពេលបច្ចុប្បន្ន ពាក្យ «គង្ហីង» មានអត្ថិភាពប្រើតែក្នុងពាក្យឬប្រើកាត់ពីពាក្យ «នាងគង្ហីងព្រះធរណី» គឺនៅរក្សាលក្ខណៈដើមដែលប្រើជាមួយមនុស្សស្រី។ ចំណែកឯពាក្យ «កំហែង» វិញ គឺសម្គាល់នូវលក្ខណៈខេងរេង កម្លាំងខ្លាំង ដែលក្លៀវក្លា អង់អាច... ប្រើជាឋានន្តរនាមផងដូចជា កំហែងហនុមាន (អ្នកសហគមន៍ស្វាយអណ្តែតហៅ អ្នកតាកំហែង) និងប្រើជាឈ្មោះទូកងផងដូចជា កំហែងរាមា កំហែងនាគរាជ កំហែងមហាហង្សសែនជ័យ ជាដើម។ ពាក្យនេះបានក្លាយពីការប្រើជាមួយស្រី មកប្រើជាមួយប្រុសផងដែរ ប៉ុន្តែពុំមែនជាប្រការចម្លែកនោះទេ ដ្បិតយើងឃើញមានពាក្យដទៃ ដែលដើមឡើយប្រើជាមួយមនុស្សស្រី ប៉ុន្តែក្រោយមកក៏ប្រើសម្គាល់ឋានៈឬតួនាទីជាធំរបស់មនុស្សប្រុសដែរ ដូចពាក្យ «មេ» ជាដើម។

---

[៧] សូមអានបន្ថែម៖ ហ៊ុន ឈុនតេង ២០១៨។



សិលាចារឹកក្រាំងព្រះពុទ្ធ K.1413



ចារឹកសីមាវត្តដើងព្រៃ មានពាក្យ នាងគុង្ហីងព្រះធនៀ(នាងគង្ហីងព្រះធរណី)

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង




រូបនាងគង្ហីងនៅរង្វង់មូលនាងគង្ហីង រាជធានីភ្នំពេញ

អត្ថបទដោយ៖ លោក ហ៊ិន ឈុនតេង



រូបនាងគង្ហីងព្រះធរណីនៅក្រោមបល្ល័ង្ករ័ត្ន វត្តអន្ទង់ក្វាន រាជធានីភ្នំពេញ




គំនូរព្រះអង្គទ្រង់ផ្ចាញ់ក្រុងមារ វត្តសំរិទ្ធិជយារាម ខេត្តកំពង់ចាម

**អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង**

# ឯកសារយោង

ញឹម សុធារិទ្ធ

២០២០. “ប្រុងពលី” https://ams.com.kh/khmercivilization/detail/574

ពុទ្ធសាសនបណ្ឌិត្យ

១៩៦៧. វចនានុក្រមខ្មែរ ភាគ១, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

ព្រាប ចាន់ម៉ារ៉ា

“ផ្កាញ់មារ”, បណ្ដាញពត៌មានវប្បធម៌ខ្មែរ, http://www.yosothor.org/publications/khmer-renaissance/chapter-two/pchanh-mea.html

ហ៊ុន ឈុនតេង

២០១៨. “សិលាចារឹកទួលក្រាំងព្រះពុទ្ធ K.1413”, កម្ពុជសុរិយា ឆ្នាំទី៦៥ លេខ២៥, ភ្នំពេញ។

ឡុង សៀម

១៩៨៧, “ឋានន្តរនាមសម័យអង្គរ”, កម្ពុជសុរិយា ឆ្នាំទី៥១ លេខ១, ភ្នំពេញ។

Vickery, M.

1998. *Society, economics, and politics in pre-Angkor Cambodia: the 7th-8th centuries*. Centre for East Asian Cultural Studies.

Jenner, P. N., & Cooper, D.

2009. *A dictionary of Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.